# ម៉ោងសម្រាកការងារដោយសារជម្ងឺដែលមិនកាត់ប្រាក់ខែរបស់ក្រុងហ្វីឡាដេលហ្វៀ

## ការលើកកំពស់សុខភាពល្អក្នុងគ្រួសារ និងកន្លែងធ្វើការ

ចូលជាធរមាន ថ្ងៃទី13 ខែឧសភា 2015

ចាប់ផ្តើមពីថ្ងៃទី**13 ខែឧសភា ឆ្នាំ2015** និយោជិកណាដែលធ្វើការយ៉ាងហោចណាស់40ម៉ោង ក្នុងមួយឆ្នាំដែលស្ថិតនៅក្នុងដែនកំណត់របស់ក្រុងហ្វីឡាដេលហ្វៀ (City of Philadelphia) នឹងមានសិទ្ធិទទួលបានការសម្រាកដោយជម្ងឺដែលមិនកាត់/កាត់ប្រាក់ខែ ។

- និយោជិកមានសិទ្ធិទទួលបានការសម្រាកដោយជម្ងឺ1ម៉ោង ចំពោះរាល់ការបំពេញការងារបានចំនួន40ម៉ោង ។
- និយោជកដែលមាននិយោជិកចំនួន10នាក់ ឬច្រើនជាងនេះ ត្រូវផ្តល់ថ្ងៃសម្រាកដោយជំងឺដែលទទួលបានប្រាក់កម្រៃដល់និយោជិករបស់ខ្លួន ។ ចំពោះនិយោជកណាដែលមាននិយោជិក9នាក់ ឬតិចជាងនេះ ត្រូវផ្តល់ថ្ងៃសម្រាកដោយសារជម្ងឺដែលមិនទទួលបានប្រាក់កម្រៃដល់និយោជិករបស់ខ្លួន ។
- ចំនួនថ្ងៃសម្រាកដោយសារជម្ងឺដែលនិយោជិកម្នាក់ត្រូវទទួលបានជាអតិបរមាគឺ40ម៉ោងក្នុងមួយឆ្នាំ ។ ថ្ងៃសម្រាកដោយសារជម្ងឺដែលនិយោជិកសន្សំបាន អាចប្រើបានពេលនិយោជិកនោះបានបំពេញការងារជាអប្បរមាចំនួន90ថ្ងៃ ។ ការសន្សំថ្ងៃសម្រាកដោយជម្ងឺនឹងចាប់ផ្តើមរាប់ចាប់ពីថ្ងៃទី13 ខែឧសភា ឆ្នាំ2015 សម្រាប់គ្រប់និយោជិកទាំងអស់ ។
- ម៉ោងសម្រាកដោយសារជម្ងឺដែលនិយោជិកម្នាក់ៗសន្សំបាន អាចត្រូវប្រើសម្រាប់តម្រូវការសុខភាពរបស់និយោជិកម្នាក់ៗ ដើម្បីមើលថែទាំសមាជិកគ្រួសារ ឬសម្រាប់សុំច្បាប់សម្រាកដែលបណ្តាលពីអំពើហិង្សាក្នុងគ្រួសារ ឬការរំលោភផ្លូវភេទ ។
- ប្រសិនបើនិយោជកបដិសេធមិនផ្តល់ថ្ងៃសម្រាកដោយសារជម្ងឺដល់និយោជិក ឬធ្វើបាបនិយោជិកណាដែលសុំច្បាប់សម្រាកដោយប្រើថ្ងៃសម្រាកដោយសារជម្ងឺ និយោជិកអាចដាក់ពាក្យបណ្តឹងជាផ្លូវការមកកាន់ភ្នាក់ងារទទួលបន្ទុកថ្ងៃសម្រាកដោយសារជម្ងឺរបស់ទីក្រុងហ្វីឡាដេលហ្វៀ បន្ទាប់ពីខែកញ្ញា ឆ្នាំ2015 ។

**ច្បាប់លេខ 141026**

**និយោជិកដែលមានសិទ្ធិទទួលបាន**

- ធ្វើការនៅក្នុងក្រុងហ្វីឡាដេលហ្វៀ
- ធ្វើការយ៉ាងហោចណាស់40ម៉ោងក្នុងមួយឆ្នាំ

**និយោជិកដែលមិនមានសិទ្ធិទទួលបាន**

- អ្នកម៉ៅការឯករាជ្យ
- កម្មករតាមរដូវកាល
- គ្រូកិច្ចសន្យា
- និយោជិកដែលត្រូវបានជួលក្នុងរយៈពេលក្រោម6ខែ
- អ្នកហាត់ការ
- និយោជិកធ្វើការមិនពេញម៉ោង
- និយោជិកស្ថិតក្នុងកិច្ចសន្យាសហជីព
- មន្ត្រីរដ្ឋការរបស់រដ្ឋ និងសហព័ន្ធ

**ព័ត៌មានសម្រាប់និយោជក**

- និយោជកដែលមាននិយោជិកចំនួន10នាក់ ឬច្រើនជាងនេះ ត្រូវផ្តល់ថ្ងៃសម្រាកឈឺដែលទទួលបានប្រាក់កម្រៃដល់និយោជិកខ្លួន ។
- ក្រុមអាជីវកម្មធំៗដែលមាននិយោជិកធ្វើការក្នុងដែនកំណត់របស់ក្រុងហ្វីឡាដេលហ្វៀ ត្រូវផ្តល់ថ្ងៃសម្រាកឈឺដែលទទួលបានប្រាក់កម្រៃ។
- និយោជកដែលមាននិយោជិកចំនួន9នាក់ ឬតិចជាងនេះ ត្រូវផ្តល់ថ្ងៃសម្រាកឈឺដែលមិនទទួលបានប្រាក់កម្រៃដល់និយោជិក ។

**និយោជកត្រូវផ្តល់ដំណឹងដល់និយោជិករបស់ខ្លួនឲ្យបានដឹងថា ពួកគេមានសិទ្ធិទទួលបានថ្ងៃសម្រាកដោយសារជម្ងឺ ចំនួនថ្ងៃសម្រាកដោយសារជម្ងឺដែលពួកគេទទួលបាន និងលក្ខខណ្ឌនៃការប្រើថ្ងៃសម្រាកឈឺដែលស្របតាមច្បាប់ ។**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ៖ paidsickleave@phila.gov

Updated 4/23/2015